www.khmerpostusa.com

សារព័ត៌មាន ខ្មែរប៉ុស្ត៍ ស.រ.អា

# KhmerPost USA

Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies

Vol. 13. Issue #300
Sept 07Th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

កិច្ចសម្ភាសន៍លោក អ៊ុំ សំអាន អំពីបញ្ហាព្រំដែន... សូមអានទៅទំព័រទី ០៣



រដ្ឋបាលបេគឺ-ប៉ូលីតូ ផ្តើមធ្វើអន្តរាគមន៏ សូមអានទៅទំព័រទី ០៥




កាន់បិណ្ឌទី៥នៅវត្តសាមគ្គី"ទិងបូរ៉ូ"... សូមអានទៅទំព័រទី ០៧



សូមឈ្វេងយល់ពីប្រវត្តិបុណ្យភ្ជុំ-បិណ្ឌ... សូមអានទៅទំព័រទី ០៨




# លទ្ធផលនៃការបោះឆ្នោតបឋមនៅឡូវែល

ដោយ ពិន សំខុន

ការបោះឆ្នោតបឋម កាលពីថ្ងៃទី១ខែកញ្ញា ២០២០ បានទទួលលទ្ធផលដ៏ពេញចិត្តមួយ ដែលសហគមន៏ខ្មែររង់ចាំ គឺអ្នកស្រីបេក្ខនារី វណ្ណា ហាវើដ ដើមកំណើតជាខ្មែរ បានជាប់ឆ្នោតនៅសង្កាត់លេខ១៧ ចំណាត់ថ្នាក់លេខមួយចំនួន ២៨៤៧សម្លេង ប្រជែងជាមួយជើងចាស់ ដេវ ណេងគ្វើល បាន១៧១០សម្លេង នឹងលីស្ហា អាកណុល បាន១២២៦សម្លេង គឺចំណោមពនាក់

តទៅទំព័រទី ១២



Vanna Howard poses in front of Cambodian Refugee Monument at Lowell City Hall, which she chaired the fundraising campaign in 2017.

## Vanna Howard Made History as the First Khmer Woman Elected to the U.S. State House of Representative

By Soben Pin

Lowell, MA — September 1st, 2020, the was a storm occurred on the Facebook community after the victory of the first ever Khmer woman, Vanna Howard, for a U.S. State Representative seat. Flooding with congratulations by individuals and organizations, many said how they believe she will represent the 17th district at "an epic level" at the State House.

Jennifer Myers "Woo hoo! Congratulation to my friend and Public Matters classmate (PM '13 the BEST class) Vanna Howard on her win in the 17th Middlesex State Rep race. Can't wait to see and work with you on Beacon Hill in January! She's an incredible woman who will represent the district an an epic level".

The Community Teamwork said "Vanna has **Continued to Page12**

## The 8th Annual Cambodia Town Film Festival to be Streaming Virtually

Sept. 16-20, 2020



*PraCh Ly, CTFF Co-founder* *Soben Pin*

By Soben Pin

Long Beach, CA — In the middle of Covid-19, theaters have been closed. The film and enter-tainment industry has suffered since the declaration of a state of emergency in March 2020. There hasn't been any movie released since the pandemic hit, however, the Cambodia Town Film Festival has found a way to bring Cambodian films to people's home, globally. The 8th Annual CTFF is scheduled to be held virtually on September 16-20, 2020. There are over 40 selected Cambodian films available to watch for free. They range from documentaries, to movies, to short films. For the past 13 years that I have been in the newspaper business, I have not come across any organization that have been able to pull together so many Cambodian films to one place at one time. This is an extraordinary work.

Prach Ly and Caylee So, Long Beach residents, established the **Continued to Page10**



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL

Excellent Service Since 1987

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍

ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ

ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្លូវច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា និងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។

បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

**PRINT READERSHIP**
*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

KhmerPost USA

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2020 PRINTING SCHEDULES

## EFFECTIVE FEBRUARY 1, 2020

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue<br>5% Savings | 3 Months (6 Issues)<br>7.5% Savings | 6 Months (12 Issues)<br>10% Savings | 12 Months (24 Issues) |
|---|---|---|---|---|
| **Full** (10" wide x 13" tall) | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" wide x 6.5" tall) | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" wide x 6.5" tall) | 165 | 940 | 1831 | 3,564 |
| **1/8** (5" wide x 3.25" tall) | 90 | 513 | 999 | 1,944 |

**Your ad is also published in our online editions of the newspaper at khmerpostusa.com**




### MONTHLY DISTRIBUTION

***70+ Locations in Lowell, MA • 7,000 copies***
***25 Locations in Lynn & Revere, MA • 1,000 copies***
***25 Locations in Providence & Cranston, RI • 2,000 copies***
***Additional distribution online***

### *Khmer Post USA Distribution Locations Include:*

*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

| 2020 PRINTING DATES | ADVERTISING DEADLINE |
|---|---|
| February 15 -Friday | February 13- Thursday |
| February 29 -Saturday | February 28-Friday |
| March 09 -Monday | March 6 - Friday |
| March 23 -Monday | March 20 - Friday |
| April 06 -Monday | April 3 - Friday |
| April 20 -Monday | April 17 - Friday |
| May 04 -Monday | May 1 - Friday |
| May 18 -Monday | May 15 - Friday |
| June 1 - Monday | May 29 - Friday |
| June 15 - Monday | June 10 - Wednesday |
| July 1 - Wednesday | June 26 - Friday |
| July 15 - Wednesday | July 10 - Friday |
| August 1 - Saturday | July 27- Monday |
| August 15 - Saturday | August 10 - Monday |
| September 1 - Tuesday | August 27 - Thursday |
| September 15 - Tuesday | September 10 - Thursday |
| October 1 - Thursday | September 26 - Saturday |
| October 15 - Thursday | October 10 -Saturday |
| November 1 - Sunday | October 27 - Tuesday |
| November 15 - Sunday | November 10 - Tuesday |
| December 1 - Tuesday | November 25 - Wednesday |
| December 15 - Tuesday | December 10 - Thursday |

***Advertising deadlines are 5 business days prior to printing date.***

### CONTACT INFO

**27 Jackson Street • Unit 329 • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

Follow us @KhmerPostUSA

Follow us @KhmerPostUSA

# កិច្ចសម្ភាសន៍លោក អ៊ុំ សំអាន អំពីបញ្ហាព្រំដែនកម្ពុជា និងវៀតណាម

ដោយៈ សុបិន ពិន

ខ្ញុំបាទ សុបិន ពិន មានកិត្តិយសដែលបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងលោក អ៊ុំ សំអាន ដែលជាអតីតសមាជិកសភាបក្សប្រឆាំងកាលពីចុងខែសីហាកន្លងទៅនេះពីបញ្ហា និងប្រវត្តិព្រំដែនរបស់ប្រទេសកម្ពុជា និងវៀតណាម ។ បងប្អូនខ្មែរយើងច្រើនតែដឹងថា យើងច្រើនមានបញ្ហាព្រំដែនយូរមកហើយជាមួយប្រទេសវៀតណាម ប៉ុន្តែមិនដឹងថា តែបញ្ហានេះផ្តើមពីចំណុចណាបានជាមានបញ្ហារបស់មកដល់ពេលបច្ចុប្បន្ននេះ ។ ផ្តើមពីចំណុចនេះលោក អ៊ុំ សំអានបានបញ្ជាក់ថា "បញ្ហានៅតាមបណ្តាយព្រំដែនកម្ពុជា-វៀត-ណាមគឺដោយសាររដ្ឋាភិបាលបានប្រើប្រាស់នូវសន្ធិសញ្ញា១៩៨៥ ដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ និងផ្ទុយពីមាត្រា៥៥នៃរដ្ឋធម្មនុញ្ញ" ។ លោកបានបន្តថា "កិច្ចព្រមព្រៀង និងច្បាប់រដ្ឋធម្មនុញ្ញនេះ បានទុកជាមោឃភាពនូវរាល់សន្ធិសញ្ញាដែលធ្វើឡើងក្នុងកំឡុងពេលដែលកម្ពុជាពុំមានឯករាជភាពក្នុងទស្សវត្តទី ៨០ ។ លោក ហ៊ុន សែន បានយកសន្ធិសញ្ញាខុសច្បាប់នេះធ្វើឱ្យមានសុពលភាពឡើងវិញនៅក្នុងឆ្នាំ ២០០៥ ។ ដោយសារតែការប្រើប្រាស់នូវសន្ធិសញ្ញាខុសច្បាប់ក្នុងសម័យយួនត្រួតត្រាបានជាធ្វើឱ្យការបោះបង្គោលបាត់បង់ដីខ្មែរនៅតាមព្រំដែន ។ ហើយលោក ហ៊ុន សែនក៏ប្រើផែនទីខុសច្បាប់ថែមទៀតដោយនៅក្នុងសន្ធិសញ្ញាឆ្នាំ១៩៨៥ មាននូវផែនទីបោនខ្នាត១ លើ ១២,០០០ របស់បារាំង និងផែនទី UTM ខ្នាត ១ លើ ៥០,០០០ របស់អាមេរិកដោយវៀតណាមជាអ្នករៀបចំឱ្យក្នុងកំឡុងពេលដែលលោក ហ៊ុន សែន ជារដ្ឋមន្ត្រីការបរទេសនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជាដោយបានចុះហត្ថលេខាក្រោមចុងកាឡុងរបស់របស់វៀតណាមជាមួយនិងរដ្ឋមន្ត្រីការបរទេសវវៀតណាមនៅសម័យនោះ ។ កាលពីពេលថ្មីៗនេះ រដ្ឋាពិបាល ហ៊ុន សែន បានចុះហត្ថលេខាទទួលយកនូវផែនទីថ្មីដែលបានបោះហើយ ៨៤% ដោយបោះពុម្ភខ្នាត១ លើ ២៥,០០០ ដោយក្រុមហ៊ុនមួយនៅប្រទេសដាណឺម៉ាកដែលបានស្នើឡើងដោយភាគីកម្ពុជា និងវៀតណាម ។ ផែនទីថ្មីនេះដូចជាផ្លូងរឹងមួយដែលយើងទទួលពីវៀតណាម" ។

លោក អ៊ុំ សំអាត បានបញ្ជាក់ថា ដោយសារការប្រើប្រាស់សន្ធិសញ្ញាឆ្នាំ ១៩៨៥ ដែលជាសន្ធិសញ្ញាខុសច្បាប់ដែលស្ថិតនៅក្រោមយួនត្រួតតា និងផែនទីUTM ខ្នាត ១ លើ ៥០,០០០ ដែលជាផែនទីខុសច្បាប់ ផែនទីថ្មីខ្នាត១ លើ ២៥,០០០ ជាផែនទីខុសច្បាប់ផងដែរ ។ គណបក្សសង្គ្រោះជាតិមិនទទួលស្គាល់ផែនទីថ្មីខ្នាត១ លើ ២៥,០០០ ដោយយួននោះទេ ។ លោកក៏បានលើកឡើងបន្ថែមផងដែរពីការដោះដូរដីរវៀងកម្ពុជា និងវៀតណាមគឺជាការដោះដូរភូមិខ្មែរនិងខ្មែរមិនមែនភូមិយួននោះទេ ដូចជាភូមិអន្លង់ជ្រៅ និងភូមិថ្លុកត្រាចដែលជាភូមិកំណើតរបស់លោក ហេង សំរិន និងភូមិពីររបស់ខ្មែរនៅតំបន់ផ្សេងទៅឱ្យយួនវិញ ដោយការប្រើប្រាស់ផែនទីមិនត្រឹមត្រូវ ។ ត្រង់ចំណុចនេះខ្ញុំបានសួរលោក អ៊ុំ សំអាតថា តើហេតុអ្វីបានជានាយករដ្ឋមន្ត្រី


អ៊ុំ សំអាន



សុបិន្ត ពិន កាសែតខ្មែរប៉ុស្តិ៍


លោក ព្រាំ ស៊ុនណារ៉ា សិក្សាពីបញ្ហាព្រំដែនខ្មែរ-វៀតណាមជាមួយលោក អ៊ុំ សំអាន

យើងអនុញ្ញាតឱ្យមានការបោះបង្គោលចូលជ្រៅទៅៗចូលមកដីខ្មែរ ហើយយកដីខ្មែរដូរជាមួយដីខ្មែរ តើមានការព្រមព្រៀងណាមួយជាមួយយួនអ្វីខ្លះទៅដែលត្រូវតែធ្វើរបៀបនេះជារៀងរាល់លើក? លោក អ៊ុំ សំអាត បានលើកឡើងថា ដោយសារលោក ហ៊ុន សែន បានកាន់អំណាចរហូតមកដល់សព្វថ្ងៃដោយសារយួនលើកបណ្តុបពីទស្សវត្តទី៨០ គាត់ដឹងគុណយួនគាត់ត្រូវកាត់ដីខ្មែរដើម្បីដឹងគុណយួន ដែលនេះជារឿងធម្មតារបស់មេដឹងកនាំមួយចំនួននៅលើពិភពលោក ដែលជំពាក់គុណបរទេស ។ លោកលើឡើងថា ការចចារគឺមិនហ៊ានធ្វើការតវ៉ាអ្វីនោះទេដោយសារទេយួនជាចៅវ៉ាយ ។ ទាក់ទាងទៅនឹងព្រំដែនសមុទ្រវិញខ្ញុំសង្កេតឃើញថាថៃ និងវៀត-ណាមបានយកដែនសមុទ្រជាប់ប្រទេសកម្ពុជាជារបស់ខ្លួនញ៉ឹងមុនកប៉ាល់កម្ពុជាពេលចង់ចេញទៅដែនសមុទ្រអន្តរជាតិត្រូវសុំការអនុញ្ញាតទៅវិញ តែយើងត្រូវធ្វើយ៉ាងដូចម្តេចដើម្បីផ្លាស់ប្តូរស្ថានភាពនេះនៅស្រុកខ្មែរ? លោក អ៊ុំ សំអាត បញ្ជាក់ថា "ជាធម្មតាដែនសមុទ្រគេយកទៅតាមច្បាប់អន្តរជាតិគឺអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីច្បាប់ដែនសមុទ្រឆ្នាំ១៩៨២ ប៉ុន្តែយួន និងលោក ហ៊ុន សែន គឺមិនបានគោរពទៅតាមអនុញ្ញានោះទេគឺគាត់ប្រើសន្ធិសញ្ញាឆ្នាំ ១៩៨២ ស្តីពីសន្ធិសញ្ញាដែនទឹកប្រវត្តិសាស្ត្រ ហើយសន្ធិសញ្ញានេះធ្វើឱ្យបាត់ដែនសមុទ្រ៣០ពាន់គីឡូម៉ែតការ៉េ និង១០ពាន់គីឡូម៉ែតការ៉េថែមទៀតដែលធ្វើឱ្យបាត់កោះត្រល់ និងកោះក្រចកសេះ ហើយនៅឆ្នាំ១៩៩៧ វៀតណាមនិងថៃចុះហត្ថលេខាដោយទ្វេរភាគីដោយគ្មានភាគីកម្ពុជាដោយថៃយកអស់៣០ពាន់គីឡូម៉ែតការ៉េទៀត ។ នៅពេលអនាគតនឹ៍ ពេលប្រទេសទាំងពីរធ្វើការកំណត់ព្រំដែនសមុទ្រ យើងនឹងបាត់ដែនសមុទ្ររបស់យើងដើម្បីចេញទៅដែនសមុទ្រអន្តរជាតិ ហើយត្រូវធ្វើការសុំច្បាប់យួន និងថៃនៅពេលអនាគតនឹ៍ ។ នៅពេលដែលយើងឃើញទូករបស់វៀតណាមមកនេសាទមកដល់មុខឆ្នេរកែប គឺដោយសារលោក ហ៊ុន សែន ធ្វើសន្ធិសញ្ញាឆ្នាំ១៩៨២ ដាក់ដែនសមុទ្រខ្មែរយួនចំនួន១០០,០០០គីឡូម៉ែតការ៉េ ។ បើយកទៅតាមសារាចររបស់លោក ប្រេ វីយេ ដែលជាគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ឆ្នាំ១៩៣៩ ការបែងចែកដែនសមុទ្ររវាងកម្ពុជា និងវៀតណាមវាគ្រាន់តែជាការគ្រប់គ្រងផ្នែករដ្ឋបាលប៉ុណ្ណោះ មិនមែនជាការបែងចែកដែនសមុទ្រនោះទេ ចំណែកការកំណត់អធិបតេយ្យភាពរបស់ប្រទេសនិមួយៗត្រូវរក្សាទុកទាំងស្រុង ។ បើតាមសារាចររបស់លោក ប្រេ វីយេ កោះត្រល់ នៅជារបស់កម្ពុជានៅឡើយនោះទេ ។ តែនៅឆ្នាំ ១៩៨២ លោក ហ៊ុន សែន បានកាត់កោះត្រល់ឱ្យទៅប្រទេសយួន ។បើគិតតាមអនុសញ្ញារស់អង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រវិញ ដែនសមុទ្ររបស់កម្ពុជាមានចំងាយ ១២ ម៉ាយ គឺស្មើរនឹង ២២.២ គីឡូម៉ែត ដូច្នេះបើគិតពីឆ្នេរកំពតដល់កោះត្រល់មានចំងាយតែ ១៥ គីឡូម៉ែតទេ និងញ៉ឹងដែនអធិបតយ្យភាពរបស់ខ្មែរគឺវាហួសកោះត្រល់រហូតល់កោះក្រចកសេះដែលយួនដណ្តើមពីកម្ពុជានៅឆ្នាំ១៩៥៧ទៅទៀត ។ បើយើងប្រើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៨៣ និងសារាចររបស់លោក ប្រេ វីយេ ឆ្នាំ ១៩៣៩ ហើយច្បាប់ជាតិ និងអន្តរជាតិផ្សេងទៀត យើងនឹងអាចទាមទាកោះត្រល់មកវិញបាន ។ ចុងបញ្ចប់លោក អ៊ុំ សំអាត ស្នើរឈប់ឱ្យលិក ហ៊ុន សែន ឱ្យឈប់បំរើយួនបន្តទៀត ហើយឈប់ប្រើប្រាស់សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ដោយយកតាមសន្ធិសញ្ញាឆ្នាំ ១៩៨៥ ហើយត្រូវឱ្យសភាលុបចោលសន្ធិសញ្ញានៅទស្សវត្តទី៨០ ហើយងាតមកប្រើសន្ធិសញ្ញាកម្ពុជាកូសាំងស៊ីនឆ្នាំ១៨៧៣វិញ ព្រមទាំងបង្គោលបារាំង១២៤ បង្គោល ទើបអាចរក្សាមរណភាពទឹកដីកម្ពុជាយើងបាន ។ លោកក៏បានស្នើឱ្យលោក ហ៊ុន សែន គោរពទៅតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ និងមាត្រាទី ៥៥ និង ២ នៃរដ្ឋធម្មនុញ្ញ ហើយត្រូវប្តឹងទៅតុលាការយុត្តិធមិអន្តរជាតិ CJ ដើម្បីនៅទីក្រុងឡាអេដើម្បីដោះស្រាយបញ្ហាព្រំដែនជាមួយវៀតណាម និងប្តឹងទៅកាន់តុលាការអាជ្ញាកណ្តាលអន្តរជាតិទាក់ទងដែនសមុទ្រ ។

# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, **M.D.**

**Sokharith Mey, M.D.**

លោក ចាន់ ទូច , **C.N.P.**

**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ

***Family Medicine***

&

សុខភាពផ្លូវចិត្ត

***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហ៊ែល. មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking

# រដ្ឋបាលបេគី-ប៉ូលីតូផ្ដើមធ្វើអន្តរាគមន៍បន្ថែមសម្រាប់សហគមន៍ដែលមានគ្រោះថ្នាក់កូវីដ១៩ខ្ពស់បំផុត

ក្រុមពង្រឹងសកម្មភាពនឹងអន្តរាគមន៍កូវីដ-១៩នឹងបន្ថែមធនធាន, ផ្ដើមបញ្ជូនសារសម្រាប់ឃោសនានៅតំបន់ ឆែលស៊ី, អ៊ីវរ៉ែត, ឡូរិន, លីន នឹង រីវែ នៅក្នុង Mass.gov/StopCOVID19

**បូស្តុន:** ទី៣កញ្ញា២០២០- ថ្ងៃនេះ រដ្ឋបាលអភិបាលរដ្ឋ បេគី-ប៉ូលីតូ បានកំណត់យកការផ្ដួចផ្ដើមគោលដៅសម្រាប់បញ្ឈប់ការរីករាតត្បាតនៃ កូវីដ១៩ នៅសហគមន៍នៃរដ្ឋដែលមានអ្នកឆ្លងមេរោគនោះច្រើនជាងគេបង្អស់។ គម្រោងផ្ដួចផ្ដើមនោះ នឹងនាំមកនូវការផ្ដោតអារម្មណ៍ខ្ពស់ទៅលើសហគមន៍ ៥ ដែលរងគ្រោះខ្លាំងជាងគេ ដែលមានអ្នកជិតខាងរស់នៅទទួលការយកចិត្តទុកដាក់ធម្មតា នឹងការយល់សារឃោសនាតាមពហុភាសាសាធារណច្រើនបែប។

ការផ្ដួចផ្ដើម ដែលផ្ដោតទៅលើការប្រឹងប្រែងនៅតំបន់ ឆែលស៊ី, អ៊ីវរ៉ែត, ឡូរិន, លីន នឹង រីវែ។ ក្រុមពង្រឹងសកម្មភាពនឹងអន្តរាគមន៍កូវីដ-១៩ (CEIT) សហការជាមួយថ្នាក់ដឹកនាំក្នុងសង្គមជាអ្នកដឹកនាំនៃការប្រឹងប្រែងនោះ។ គោលដៅនៃការផ្ដួចផ្ដើមនោះ កិច្ចប្រជុំធម្មតារវាងថ្នាក់ដឹកនាំសហគមន៍ដើម្បីស្វែងយល់ពីកិច្ចការរស់នៅនឹងកិច្ចការរកស៊ីក្នុងតំបន់ ដែលត្រូវចូលរួមពង្រឹងនឹងផ្ដោតអារម្មណ៍របស់រដ្ឋឱ្យបានខ្ពស់ ដើម្បីបញ្ឈប់ការរីករាលដាល, ហើយនឹងសារសាធារណៈសម្រាប់ការឃោសនាថ្មីទៀត។

គោលដៅនៃសារសាធារណៈសម្រាប់ឃោសនា គឺដើម្បីធានាពលរដ្ឋក្នុងតំបន់ថាៈ ពួកគេប្រាកដជារស់នៅក្នុងតំបន់ ដែលសហគមន៍អាចមានការគ្រោះថ្នាក់ជាងគេបង្អស់ ហើយបង្កលក្ខណៈរំលឹកពីសារសំខាន់នៃការពាក់របាំងមុខនឹងវិធីល្អផ្សេងទៀតសម្រាប់បញ្ឈប់ការឆ្លងបន្តគ្នា។ ក៏សាងជុំវិញសារថា "អ្នកមានអំណាចសម្រាប់ជួយជីវិត"។ ការដែលយល់ពិសារនោះ គឺការលើកទឹកចិត្តឱ្យប្រើរបាំងមុខនឹងអនុវត្តន៍គម្លាតសង្គម ដែលមានជាភាសាអង់គ្លេស, ព័រទូគ្លេស, ស្បាញ៉ុល, ហៃទី, វៀតណាម, ខ្មែរ នឹងភាសាដ៏ទៃទៀត ដែលគេនិយាយច្រើនគ្នា។ ការឃោសនានោះមានៈ

-ការប្រើវេបសាយថ្មី Mass.gov/StopCOVID19

-ការផ្សព្វផ្សាយលើផ្ទាំងផ្សាយធំៗ, តាមឌីជីថល, រតាមប្រព័ន្ធផ្សព្វផ្សាយសង្គម

-ស្រូបយកព័តិមានជាភាសាច្រើនសាសន៍

-ក្រុមផ្សព្វផ្សាយពហុភាសាផ្ដើមធ្វើការក្នុងសហគមន៍

-ទាក់ទងតាមទូរស័ព្ទ ឬផ្ញើរសារតាមទូរស័ព្ទទៅសហគមន៍

-ចេញទៅជួបក្រុមសហគមន៍ក្នុងតំបន់

វេបសាយថ្មី Mass.gov/StopCOVID19 ផ្ដល់ជូនដល់សហគមន៍នឹងម្ចាស់ពាណិជ្ជកម្មក្នុងតំបន់នូវព័តិមានថា "តើត្រូវបញ្ឈប់ការរីករាលដាលយ៉ាងណា? បទបញ្ជារបស់រដ្ឋសម្រាប់រៀបចំកន្លែងទទួលភ្ញៀវ, កន្លែងធ្វើ "តែស", ហើយនឹងប្រដាប់ប្រដារសម្រាប់បោះពុម្ពតាំងផ្សាយ នៅតាមផ្ទះសំណាក់, តាមភោជនីយដ្ឋាន, នឹងតាមទីសហគមន៍..."។

ការឃោសនតាមការផ្សាយពាណិជ្ជកម្មៈ នឹងមានការបង្ហាញការផ្សព្វផ្សាយនោះនៅច្រើនពាន់កន្លែង ជាសារលើផ្ទាំងផ្សាយពាណិជ្ជកម្ម, ជាផ្ទាំងបោះពុម្ព, ជា "ប៊ិលប័ដ" នឹងកម្មវិធីផ្សាយ




របស់សហគមន៍កំពូលទាំង៥ តាមរយៈការរួមកម្លាំងជាមួយដៃគូរ ដោយមានកម្រៃនឹងជាមួយធនធានរបស់រដ្ឋ, ដូចជានៅចំណតរថយន្តក្រុង, ផ្ទាំងផ្សាយរបស់ MassDOT នឹងធនធានច្រើនទៀត។ ក្នុងឱកាសឈប់សម្រាកបុណ្យការងារ ក្រុមការងារប្រចាំតំបន់ នឹងមានសកម្មភាពនៅប្រមាណ១៥កន្លែង នៅសហគមន៍កំពូលទាំង៥នោះ ។ គ្រប់ភិនភាគនៃការឃោសនានោះនឹងបន្តរនៅរដូវរំហើយទៀតផង។

ចាប់ពីដើមខែសីហានេះទៅ រដ្ឋបាលបានបង្កើតក្រុម CEIT ដែលជាទីបញ្ជាការប្រយុទ្ធកូវីដ១៩។ CEIT គឺជា "អង្គភាពចម្រុះសម្រាប់ឆ្លើយតប" ក្នុងនោះមានដំណាង Community TracingCollaborative, អង្គភាព Public Health, អង្គភាព Alcoholic Breverages control commission, Mass State Police, Departement of Labor Standarts នឹងអង្គដ៏ទៃជាច្រើនទៀត។

ចាប់តាំងពីក្រុមនេះបានបង្កើតឡើង គេបានធ្វើការយ៉ាងជិតស្និតជាមួយសហគមន៍ដែលមានគ្រោះថ្នាក់ខ្ពស់ដើម្បីជួយបញ្ឈប់ការរីករាលដាលនៃកូវីដ១៩ នៅតំបន់ដែលនៅតែការឆ្លងជម្ងឺនៅតែខ្ពស់ជាងមធ្យមមិនចេះចប់។ CEIT សហការជាមួយអ្នកជាប់ឆ្នោតនឹងសហគមន៍ផ្លូវការមានជាអាទិ៍ ថ្នាក់ដឹកនាំនៅសាលាក្រុង, មេប៉ូលីស,

តទៅទំព័រទី០៦

# BAKER-POLITO ADMINISTRATION LAUNCHES ADDITIONAL INTERVENTION INITIATIVES FOR COMMUNITIES WITH HIGHEST RISK FOR COVID-19

COVID-19 Enforcement and Intervention Team to Add Resources, Begin Public Messaging Campaign for Chelsea, Everett, Lawrence, Lynn and Revere with Mass.gov/StopCOVID19

BOSTON – September 3, 2020 – Today, the Baker-Polito Administration stepped up its targeted initiative to help stop the spread of COVID-19 in communities across the Commonwealth with the highest number of positive cases. This initiative brings even greater focus to the top 5 highest-risk communities with regular neighborhood-level assessments and a comprehensive multi-lingual public messaging campaign.

The initiative focuses efforts on Chelsea, Everett, Lawrence, Lynn and Revere. The Commonwealth's COVID-19 Enforcement and Intervention Team (CEIT), in partnership with local community officials, is leading this effort. This targeted initiative includes regular meetings with local leadership to understand local residential and business activities contributing to trends, an even greater level of state focus to stop the spread and a new public messaging campaign.

The goal of the public messaging campaign is to ensure residents know they live in a high-risk community and reiterate the importance of wearing a mask and other best practices to stop the spread. Built around a message of, "You have the power to save a life," the comprehensive campaign will encourage the use of masks and social distancing and will run in English, Portuguese, Spanish, Haitian, Vietnamese, Khemer and other languages common to these communities. The campaign includes:

- A new website platform at Mass.gov/StopCOVID19
- Advertising on billboards, digital and social media
- Downloadable materials in multiple languages
- Multi-lingual field teams deployed in the communities
- Phone and text communications
- Outreach to local community groups

This new website Mass.gov/StopCOVID19 provides residents and local business owners with information on how to stop the spread, state restrictions on gathering sizes, testing locations and materials that can be printed for display in apartment complexes, restaurants and community areas.

The campaign's advertising will run on hundreds of displays, message boards, signs, billboards and other channels in these top 5 communities through paid partnerships and via state-owned resources, such as at MBTA stations, MassDOT signs and much more. During Labor Day weekend, the field teams will be active at approximately 15 locations in these top 5 communities. All aspects of this campaign will expand throughout the fall.

In early August, the Administration established the CEIT through the COVID-19 Command Center. CEIT is a cross-agency response unit which includes representatives from the Community Tracing Collaborative, Department of Public Health, Alcoholic Beverages Control Commission, Massachusetts State Police, Department of Labor Standards and other agencies.

Since it was launched, this team has worked closely with all higher-risk communities to help stop the spread of COVID-19 in areas that are persistently above the state average. CEIT partnered with local elected and community officials, including municipal leadership, police chiefs and local health departments, to assess trends and most effectively utilize resources. Collectively, these teams have enforced gathering size restrictions and shared with municipalities

Please Read Page 06

## តមកពីទំព័រទី ០៥ រដ្ឋបាល បេគឺ-ប៉ូលីតូ ផ្ដើមធ្វើ....

អង្គការសុខភាពក្នុងតំបន់ ដើម្បីពង្រឹងលទ្ធភាពនឹងប្រើធនធានឱ្យបានប្រយោជន៍ជាទីបំផុត ។ ធ្វើការជារួមគ្នាក្រុមការងារបានពង្រឹងបទបញ្ញត្តិនៅទីកន្លែងទទួលភ្ញៀវ ហើយចែករំលែកជាមួយសាលាក្រុងនូវជំនួយបន្ថែមពីរដ្ឋ ដូចជាធ្វើ "តេស" នឹងទំនាក់ទំនងសម្រាប់ទទួលព័តិមាន ។


លោកស្រី ប៉ូលីតូ អភិបាលរដ្ឋរង និងលោក បេគឺ

នៅក្នុងរដ្ឋទាំងមូលមធ្យមភាគនៃការគ្រោះថ្នាក់រាល់ថ្ងៃ គឺ៤នាក់ក្នុង១០ម៉ឺននាក់, ចំណែកឯនៅឆែលស៊ីមាន៣១.៨៦, នៅ រីវែរ ២០.៤០, នៅលីនមាន១៦.៧១,អ៊ីវរ៉ែត១៣.៦៩ នឹងនៅ ឡូរិនមាន១០.0៤ ។ ដោយសារស្ថិតិថ្មីរបស់សហគមន៏បានត្រូវចេញផ្សាយ, CEIT នឹងកែតម្រូវក្រុងនឹងប្រជុំជនឱ្យចេញពីក្រុមនៃទីក្រុងនឹងប្រជុំជន ដែលប្រកបដោយគ្រោះថ្នាក់ខ្ពស់ ។ បន្ទាប់ពីខែកញ្ញាទៅការឃោសនានឹងត្រូវពង្រីកទៅក្រៅពីសហគមន៏កំពូលទាំង៥នោះហើយ ។

ប្រែសម្រួលដោយខ្មែរផុសស.រ.អា

---

### BAKER-POLITO ADMINISTRATION LAUNCHES
*/From Page 05*

additional state support, such as testing and contact tracing information.

The statewide average daily incidence rate is 4 cases per 100,000 people, while Chelsea is 31.86, Revere is 20.40, Lynn is 16.71, Everett is 13.69 and Lawrence is 10.04. As new community data is reported, CEIT will adjust as cities and towns as communities move into or out of higher-risk categories. Throughout September the campaign will expand beyond the top 5 communities.

# ជំនួយសង្គ្រោះ"Unemploy.-Stimullus"ដល់ណាហើយ?

យើងបានបាត់ដំណឹងមួយរយៈហើយពីជំនួយដល់ពលរដ្ឋគ្រប់គ្នាជាពិសេសជំនួយដល់គ្រួសារក្រីក្រ ដែលត្រូវការការគាំទ្រពីសហព័ន្ធ ដើម្បីតទល់នឹងជម្ងឺរាតត្បាត "កូវីដ១៩" ស្រាប់តែបាត់ដំណឹងសូន្យឈឹង ។ប៉ុន្តែបើតាមផារផ្សព្វផ្សាយដ៏គួរឱ្យជឿបាន គឺនៅព្រឹទ្ធសភាមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំង រវាងគណបក្សសាធារណរដ្ឋដែលមិនចង់ចាយលុយច្រើន១ឱ្យចាយតែ១.៥ ទ្រីល្យុង) រីឯខាងគណបក្សប្រជាធិបតេយ្យដែលចង់ឱ្យមានការចែកចាយដល់សារជីវកម្មខ្នាតតូច១ នឹងដល់គ្រួសារក្រីក្រផង១ឱ្យចាយ២ .៥ទ្រីល្យុង) សភានឹងបើកការចរចារទៀត ជាមួយរដ្ឋលេខាហិរញ្ញវត្ថុផងនៅសប្ដាហ៍ក្រោយ ។

សម្រាប់អ្នកឥតការងារធ្វើ (Unemploy) ដែលឥឡូវឡើងដល់ជិត១លាននាក់, សេចក្ដីប្រកាសបានចេញមកហើយ ដោយលោកប្រធានាធិបតី ត្រាំ បានចុះហត្ថលេខា មុនពេលមានការព្រមព្រៀងនៅសភាទៅទៀត ដែលជាហេតុជម្រុញសភាឆាប់ត្រូវគ្នាលើជំនួយដល់អ្នកឥតការធ្វើតែខាងបេឡាមិនអាចបញ្ចេញប្រាក់បានទេ បើសភាមិនទាន់អនុម័តទេនោះ។ ឥឡូវប្រាក់ឥតការងារធ្វើនោះ នឹងទទួលបន្ថែម ចំនួន៣00ដុល្លារគិតចាប់តាំងពីថ្ងៃទី២៧ ខែកក្កដាមក រហូតដល់ដាច់ឆ្នាំ ។ ចំណែក ឯខាង "ស្ទីមិឡើស១២00ដុល្លារ នឹងកូន ៥00ដុល្លារ" វិញ សភានៅពុំទាន់មានការ ព្រមព្រៀងគ្នានៅឡើយទេ ហើយក៏ពុំទាន់មានការចុះហត្ថលេខាអ្វីពីប្រធានាធិបតីក៏ទេដែរ ។

គេសង្ឃឹមថា អ្វី១នឹងត្រូវបញ្ចប់ នាសប្ដាហ៍ខាងមុខនេះហើយពីព្រោះព្រឹទ្ធសភានឹងចូលធ្វើការវិញនៅសប្ដាហ៍នោះ ហើយដោយសារ ឱកាសបោះឆ្នោតប្រធានាធិបតី ក៏កាន់តែខិតមកជិតទៀត លោក ត្រាំ ក៏មិនចង់ឱ្យខូចប្រជាប្រិយភាពដោយសាររឿងនេះទេ។






# កាន់បិណ្ឌទី៥នៅវត្តសាមគ្គី“ទិងប្បូរ៉”

ដោយៈ ពិន សំខុន

ភ្ញៀវបានមកកុះករ នាវរសៀលថ្ងៃអាទិត្យទី"ដើម្បីផ្ដើមពិធីកាន់បិណ្ឌរបស់លោកអាចារ្យ ធូ សារឿន នឹងភរិយា ដែលបានចាប់ផ្ដើមចំនួន៥ថ្ងៃមកហើយ នៅវត្តសាមគ្គីសន្តិការាមដែលនៅលើផ្លូវទៅ"ទិងប្បូរ៉"រដ្ឋម៉ាសាឈូសិត ជាភូមិមួយនៅជាប់គ្នានឹងក្រុងឡូវែល។ ក្នុងសម្បៀកបំពាក់ប្រពៃណីខ្មែរប្រជាពលរដ្ឋជាពុទ្ធសាសនិកបានមកធ្វើបុណ្យឡើងហួសចំណុះដែលរដ្ឋបាលបូស្តុនបានកំណត់ឱ្យទៅហើយ។ គេបានអង្គុយដិកង់សូត្រធម៌ព្ទរងំដៃពូតបាយជាដុំតូចៗ ហៅ"បាយបោះ"នាល្ងាចបិណ្ឌ៥នោះទុកសម្រាប់សែនឱ្យ"ប្រេត"ដែលនឹងមកទទួលម្ហូបពីកូនចៅ នាពេលព្រឹកឡើង។ ព្រះសង្ឃក៏បាននិមន្តមកសម្ដែងធម៌យ៉ាងវែង នាពេលបន្ទាប់មកចែកជូនពុទ្ធសាសនិក ចែកជូនអ្នកដែលបានចែកឋានទៅហើយឧប្បត្តិកិច្ចឱ្យជីវិតនៃក្រុមប្រេត បានទទួលអនិសង្សគ្រប់ៗគ្នាពីវត្តសាមគ្គីនឹងពីកូនចៅរបស់គេ ។

វត្តនេះជាវត្តថ្មីបំផុត នៅម្តុំឡូវែល ដែលបានបែកចេញពីវត្ត"ត្រៃរតនារាម" ក្នុងជម្លោះរ៉ាំរ៉ៃរាប់សិបឆ្នាំ រវាង"វត្តលើ-វត្តក្រោម" ទើបតែបញ្ចប់កាលពី៣-៤ឆ្នាំមុន ដោយការចាកចេញរបស់វត្តក្រោមទៅបង្កើតវត"សាមគ្គី..." នឹងបន្ទាប់ពីព្រះគ្រូ សៅ ឃន ចៅអធិការវត្តត្រៃរតនារាមដំបូងគេ ក៏បានដកខ្លួនចាកចេញមុនគេកាលពី៥-៦ឆ្នាំមុន ទៅរកបង្កើតវត្តមួយនៅត្រើយម្ខាង ហៅ"វត្តខ្មែរឡូវែល"។ មិនទាន់ចប់ទេ កាលពី២ឆ្នាំមុន នៅមានព្រះគ្រូចៅអធិការវត្តត្រៃរតនារាម មី ឡែម ក៏បានចាកចេញពីវត្តដំដែលនេះដែរ ដោយមិនដឹងហេតុផលទៅជួលកុដិមួយនៅជិតហាង"ហុងកុង"សម្រាប់ប្រារព្ធពិធីសាសនាមួយដែរ។ នៅខ្វះការចាកចេញមួយទៀត គឺដោយសារមានរឿងអាស្រូវនៅវត្តត្រៃរវាងព្រះសង្ឃនឹងស្ត្រីជើងវត្ត ដែលមានគេលួចថតវីដេអូបាន ក៏ព្រះសង្ឃបរាជិក ញែម គឹមតេងក៏បានចាកចេញទៅបង្កើតកុដិខ្លួនឯងមួយទាំងមិនព្រមចាកសិក្ខាបទ ទៅរស់នៅផ្លូវ"ផវែល" ដែលគឺជាការបែកចេញជា៥ផ្នែក ពីវត្តត្រៃរតនារាម នាតំបន់ក្បែរគ្នានឹងឡូវែលដែរ គឺពីឆែមហ្វ៊ីត។







នា២-៣ឆ្នាំចុងក្រោយនេះ វត្តសាមគ្គីរៀបចំបានជាព្រះវិហារថ្មី ដ៏ស្រស់ស្អាតមួយ ហើយពង្រីកដីនៅក្បែរគ្នាបានមួយឡូត៍ទៀត ទៅជាទីធ្លាដ៏ធំទូលាយ គ្រប់គ្រងវត្តដោយព្រះគ្រូចៅអធិការ សែម សារិន តែមួយអង្គឯង មិនមានសមាជិកគណកម្មការវត្តឯទៀតណា អាចមកឈ្លោះ ប្រកែកដណ្តើមអំណាចក្នុងវត្តថ្មីនេះ ដូចពេលមុនបានឡើយ។ មែនហើយភាពស្ងប់ស្ងាត់មិនប្រទាញប្រទង់គ្នា បានកើតឡើងមែន នាពេលនេះ ដែលជាហេតុធ្វើឱ្យវត្តសាមគ្គី បានប្រែរូបសោភ័ណ្ឌភាពបានយ៉ាងឆាប់រហ័ស ។

ព្រឹកឡើង"បាយបោះ"របស់ក្រុមបិណ្ឌ៥បានយកទៅបោះនៅតាម ទីលានមានស្មៅ នាម៉ោង៥ព្រហ៊ាម ដែលគេសន្មត់ថា "ប្រេត"នឹងមកទទួលបាយបោះនោះ នៅជុំវិញវត្ត ជាមិនខានឡើយ ។នៅម៉ោង៧ព្រឹក មានការប្រគេនចង្ហាន់ស្រស់ស្រូបដល់ព្រះសង្ឃ" ពេលម៉ោង៩ មានទ័យទានសម្រាប់ប្រគេនព្រះសង្ឃនឹងបរិក្ខាផ្គត់ផ្គង់វត្តពុទ្ធបរិស័ទបានមកជួបជុំគ្នាម្តងទៀត ដើម្បីសូត្រមន្តប្រគេនចង្ហាន់ត្រង់នឹងវេរឥវ៉ាន់ទាំងអស់ប្រគេនព្រះសង្ឃជាកិច្ចបញ្ចប់ពិធីបុណ្យកាន់បិណ្ឌ។

នាថ្ងៃបិណ្ឌទី៥នោះ ម្ចាស់ផ្តើមបុណ្យបានប្រមូលបច្ច័យប្រគេនព្រសង្ឃបាន៣៣00ដុល្លារ ។






មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

# ថ្ងៃនេះបិណ្ឌ៩ ! សូមឈ្វេងយល់អំពីប្រវត្តិ ពិធីបុណ្យភ្ជុំបិណ្ឌជាទំនៀមទម្លាប់របស់បងប្អូនប្រជាជនខ្មែរ!

ភ្នំពេញ ៖ បុណ្យភ្ជុំបិណ្ឌជាពិធីបុណ្យមួយដែលធំជាងគេ នៅក្នុងចំណោមពិធីបុណ្យទាំងអស់ ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា។ ជារៀងរាល់ឆ្នាំនៅពេលដល់ថ្ងៃខែ ដែលត្រូវប្រារព្ធ ពិធីបុណ្យភ្ជុំ បិណ្ឌ គ្រប់បងប្អូនកូនចៅសាច់ញាតិសន្ដានទាំងអស់ ទោះនៅទីជិត ឬទីឆ្ងាយ តែងតែធ្វើដំណើរទៅជួបជុំគ្នា ជាពិសេសឪពុកម្ដាយនៅស្រុកកំណើត ដើម្បីរៀបចំម្ហូបអាហារ បាយសម្ល ចង្ហាន់យកទៅប្រគេនព្រះសង្ឃ ដែលគង់នៅវត្តអារាម។ ទាំងនេះ គឺជាទម្លាប់មួយដែលគេនិយមធ្វើត។គ្នារបស់ជនជាតិខ្មែរជាយូរមកហើយ។

ពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌឆ្នាំ២០២០នេះប្រព្រឹត្តទៅចាប់ពីថ្ងៃ១រោច ដល់ថ្ងៃ ១៤រោច ខែភទ្របទ ត្រូវនឹងថ្ងៃទី០៣ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២០។




## ប្រវត្តិបុណ្យភ្ជុំបិណ្ឌ

បើតាមតម្រាចារតាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បានបង្ហាញថា ពិធីបុណ្យភ្ជុំបិណ្ឌ គឺកើតមានតាំងពីបុរាណកាលមកម្ល៉េះ។ ប៉ុន្តែទាស់ត្រង់ថា កាលពីសម័យមុនគេមិនហៅថា បុណ្យភ្ជុំទេ ដោយនៅក្នុងពិធីនេះ គេមានបែងចែកចេញជាពីរថ្នាក់។ ថ្នាក់ដំបូង គឺគេចាប់ផ្ដើមធ្វើចាប់ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៤រោច ជាវារកភត្ត (ភត្តធ្វើតាមថ្ងៃ) ជាបន្តបន្ទាប់។ ចំណែកមួយថ្នាក់ទៀតគេធ្វើនៅថ្ងៃ ១៥រោច ដែលគេហៅថា បុណ្យភ្ជុំ។ ពិធីបុណ្យទាំងពីរថ្នាក់នេះ បច្ចុប្បន្នត្រូវបានយើងបូកបញ្ចូលគ្នា ហើយហៅកាត់ថា ពិធីបុណ្យបិណ្ឌភ្ជុំ។

## មូលហេតុដែលប្រារព្ធពិធីបុណ្យភ្ជុំ

កាលពីសម័យបុរាណកាល គេធ្វើពិធីបុណ្យនេះ គឺដើម្បីរៀបចំធ្វើសង្ឃភត្ត ទំនុកបម្រុងព្រះសង្ឃ ដែលគង់ចាំវស្សាក្នុងវត្តរយៈពេល ៣ខែ ចាប់តាំងពីថ្ងៃចូលវស្សារហូតដល់ថ្ងៃចេញវស្សា។ នៅក្នុងចំណេរកាលបុរាណបានចារថា ដោយនៅក្នុងរដូវវស្សាមានភ្លៀងធ្លាក់ជោកជាំរលឹមពព្រិច ធ្វើឱ្យមានការលំបាកដល់ព្រះសង្ឃក្នុងពេលធ្វើគោចរ (ដើរ) បិណ្ឌបាត។ ហេតុដូច្នេះ ទើបបណ្ដាពុទ្ធបរិស័ទនាំគ្នារៀបចំពិធីនេះ ដើម្បីផ្គត់ផ្គង់ព្រះសង្ឃប្រចាំថ្ងៃរហូតដល់ថ្ងៃចេញ



វស្សា។ ម្យ៉ាងវិញទៀត នៅក្នុងពិធីបុណ្យនេះ គឺធ្វើឡើងដើម្បីផ្សាយឧទ្ទិសកុសលដល់ពពួកប្រេតជនញាតិ និងញាតិទាំង ៧សណ្ដាន ព្រមទាំងតំណញាតិច្រើនមហាកប្បនោះផងដែរ តាមរយៈអនុភាពនៃសង្ឃគតាទក្ខិណាទាន ដែលរស់រងទុក្ខវេទនា កើតជាប្រេតមានកម្មពៀរជាប់ទោសធ្ងន់រងកម្មក្រហល់ក្រហាយអត់ឃ្លានទាំងអស់នោះ បានរួចផុតពីក្ដីលំបាកសោកសៅ។

## រដូវបុណ្យភ្ជុំបិណ្ឌ

ចាប់តាំងពីសម័យបុរាណកាល រហូតមកដល់បច្ចុប្បន្ននេះ ពិធីបុណ្យភ្ជុំបិណ្ឌនេះ គេតែងតែប្រារព្ធនៅក្នុងរដូវវស្សា ព្រោះនៅក្នុងរដូវនេះ ពពួកប្រេតអាចមានឱកាសច្រើនក្នុងការស្វែងរកចំណីអាហារជាងរដូវផ្សេង។ទាំងអស់។ ម្យ៉ាងវិញទៀតនៅក្នុងវស្សានរដូវ អាហាររបស់ពួកប្រេត ដូចជាភក់ជ្រាំ ស្លេស្ម កំហាក សាកសពនិងកាកសំណល់អសោចសម្បូរនៅក្នុងខែភ្លៀងផ្គរពព្រិច។ នៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌរយៈពេល ១៥ថ្ងៃនេះ មានពពួកប្រេតជន (ពួកប្រេត) សាច់ញាតិទាំងប្រាំពីរសណ្ដាន ព្រមទាំងតំណ-ញាតិច្រើនមហាកប្ប ដែលអត់ឃ្លានអាហារអស់រយៈពេលជាច្រើនខែមកហើយនោះ ត្រូវបានរួចផុតពីការឃុំឃាំង អនុញ្ញាតឱ្យមកស្វែងរកសាច់ញាតិនៅតាមវត្តអារាមផ្សេង។ ដែលនាំយកចំណីអាហារផ្សេង។ មកឧទ្ទិសកុសលឱ្យខ្លួន។ ម្យ៉ាងវិញទៀត បើតាមសម្ដីចាស់។បុរាណនិយាយត។គ្នាថា ក្នុងរយៈពេល១៥ថ្ងៃ បើពពួកប្រេតជនទាំងអស់នោះ ដើរស្វែងរកញាតិចំនួន៧វត្តនៅតែមិនឃើញនោះ ពពួកប្រេតទាំងអស់នោះនឹងស្រែកយំទន្ទ្រាំជើង ព្រោះតែការខកបំណងនិងភាពស្រេកឃ្លានក្រហល់ក្រហាយក្នុងចិត្ត។ ជាពិសេសពពួកប្រេតជនទាំងអស់នោះ នឹងជេរដាក់បណ្ដាសាដល់សាច់ញាតិកូនចៅជាមិនខាន។

## ការប្រារព្ធពិធីបុណ្យបិណ្ឌភ្ជុំ

ចំពោះបុណ្យបិណ្ឌភ្ជុំនេះ បុរាណាចារ្យរាជបណ្ឌិតខ្មែរ យើងបានរៀបចំរយៈពេល១៥ថ្ងៃ ដោយចាប់គិតពីថ្ងៃទី១រោច ដល់ថ្ងៃទី១៥រោច ខែភទ្របទ ជាពិធីមួយសម្រាប់ឧទ្ទិសកុសលទៅដល់ប្រេតជនញាតិដែលបានស្លាប់ទៅ។ នៅក្នុងរយៈពេល១៤ថ្ងៃ នៃការកាន់បិណ្ឌ ឬដាក់បិណ្ឌនេះ ពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់ ជាពិសេសក្រុមនីមួយ។ ដែលបានរៀបចំជាក្រុមដោយលោកតាអាចារ្យចាត់ចែងនោះ ត្រូវបែងចែកចេញ ៣ ឬ៤ក្រុមតូច។ ដើម្បីរៀបចំធ្វើយាគូ (បបរ) ឬធ្វើភត្តាហារជា ៣ ទៅ ៤ឆ្នាំងស្មើនឹង ៣ ទៅ ៤មុខម្ហូប។ ពេលទូងស្គរចំណាំវស្សាអ្នកនៅក្នុងក្រុមវេននីមួយ។ត្រូវចាប់ផ្ដើមធ្វើចង្ហាន់ ហើយយាយតាចាស់។ ក្នុងក្រុមវេនត្រូវជ្រើសរើសយកផ្ទះណាមួយ ដើម្បីប្រមូលនំរៀបចំបាយបិណ្ឌ បាយបត្តបូរ។ រៀបចំរួចហើយត្រូវនាំគ្នាទៅវត្តស្ដាប់លោកសង្ឃសូត្រថ្វាយបង្គំធមិ សុខោ និង ធមិបរាភវសូត្រ។

ចំណែកឯកូនចៅដែលនៅផ្ទះត្រូវនាំគ្នាខិតខំដុតដៃដុតជើងបបរ ឬស្លតាមមុខម្ហូបនីមួយ។ ដោយឡែកពីគ្នា។ លុះដល់ពេលព្រឹកព្រាងអរុណោទ័យ (ពេលព្រះអាទិត្យរះឡើង) ត្រូវនាំគ្នារៀបចំខ្លួន កណ្ដៀត យួរ កាន់ ទូល រែកចង្ហាន់ទៅវត្ត។ នៅក្នុងវត្តលោកតាអាចារ្យត្រូវរៀបចំពិធីរាប់បាត្រនៅលើឧបដ្ឋានសាលា។ បន្ទាប់មកលោកអាចារ្យជាប្រធានត្រូវនាំពុទ្ធបរិស័ទវេរ (ប្រគល់) ចង្ហាន់ប្រគេនព្រះសង្ឃវេរបាយបត្តបូរ។ល។ លុះដល់ពេលព្រះសង្ឃធ្វើបត្តានុមោទនគាថាចប់ មេវេនក្រុមនីមួយ។ត្រូវរៀបចំម្ហូបអាហារចំណីចូលគំនាប់ជូនលោកតាអាចារ្យវត្ត ព្រមទាំងចាត់ចែងភោជ នាហារទទួលភ្ញៀវដែលអញ្ជើញទៅបុណ្យ នៅក្នុងថ្ងៃវេនរបស់ខ្លួននោះផងដែរ។

ដោយ FreshNews

# CAMBODIA: FREE DETAINED YOUTH, ENVIRONMENTAL ACTIVISTS

## End de Facto Ban on Phnom Penh Protests

Published in Human Rights Watch

(Bangkok) – The Cambodian authorities should immediately drop baseless-incitement charges against 14 recently detained youth and environmental activists and unconditionally release them, Human Rights Watch said today.

The authorities have arrested the 14 since August 2020 for organizing or taking part in peaceful protests. Eleven of them were held for calling for the release of a detained union leader, Rong Chhun.

Youth activists had planned an eight-day protest at the designated protest area, End de Facto Ban on Phnom Penh Protests Published in (Bangkok) – The Cambodian authorities should immediately drop baseless incitement charges against 14 recently detained youth and environmental activists and unconditionally release them, Human Rights Watch said today.

The authorities have arrested the 14 since August 2020 for organizing or taking part in peaceful protests. Eleven of them were held for calling for the release of a detained union leader, Rong Chhun.

